ខែសីហា ឆ្នាំ២០០៧/**August 2007**
**SHPN (CBD) 07/136KH (Khmer)**

# កិច្ចបំរើគ្រប់គ្រង និងការពារជម្ងឺរបេង រដ្ឋញូវសៅវែល
# NSW Tuberculosis Prevention & Control Service

## រោគរបេងដែលមិនទាន់លេចចេញឲ្យឃើញ (LTBI) និងការព្យាបាលដើម្បីបង្ការរោគ

- វេជ្ជបណ្ឌិតរបស់លោកអ្នកបានចេញនូវមុខថ្នាំពេទ្យជូនលោកអ្នក ដើម្បីបង្ការរោគរបេង (TB)។
- ការព្យាបាលនេះបានផ្តល់ជូនលោកអ្នកដោយព្រោះថាលោកអ្នកមាន:
  - ការធ្វើតេស្តស្បែកវិជ្ជមានដើម្បីរកមើលរោគរបេង (បានគេហៅដែរថាតេស្ត TST ឬតេស្ត Mantoux) ឬ
  - ការថតមើលដើមទ្រូងដោយកម្មរស្មីអិក្ស ដែលបង្ហាញឲ្យឃើញភាពខុសប្រក្រតី ឬ
  - ធ្លាប់បានទាក់ទងជាមួយជនណាម្នាក់ដែលមានរោគ TB។
- ការទាំងនេះបញ្ជាក់ឲ្យឃើញថាលោកអ្នកទំនងជាមានរោគ TB ដែលអាចនាំឲ្យកើតទៅជាជម្ងឺរបេង។

### តើរោគ TB និងជម្ងឺ TB ខុសពីគ្នាយ៉ាងដូចម្តេចដែរ?

**រោគ TB:**

- ការមាន TST វិជ្ជមាន បញ្ជាក់ថាមានរោគ TB។
- កាលណាជនណាម្នាក់មានរោគ TB នោះគេមានមេរោគ TB នៅក្នុងដងខ្លួនរបស់គេ ក៏ប៉ុន្តែមេរោគទាំងនោះមិនសកម្មឡើយ ហើយក៏មិនអាចចម្លងទៅអ្នកឯទៀតដែរ។
- នៅក្នុងករណីភាគច្រើន (៩០-៩៥%នៃប្រជាជន) ប្រព័ន្ធស៊ាំនឹងរោគរបស់ដងខ្លួនគ្រប់គ្រងមេរោគទាំងនោះ ហើយជម្ងឺ TB នឹងមិនអាចកើតបានឡើយ។
- អស់អ្នកដែលមានរោគ TB តែមួយមុខនោះពុំមានរោគសញ្ញាអ្វីឡើយ ហើយគេមានអារម្មណ៍ល្អទេ។

**ជម្ងឺ TB:**

- នៅក្នុងចំណោមមនុស្សប្រមាណជា៥-១០% ដែលមានរោគ TB ជម្ងឺ TB អាចកើតមានឡើងពេលណាមេរោគ TB អសកម្ម ក្លាយទៅជាសកម្ម ហើយកើនចំនួនរបស់វា។
- ការនេះអាចកើតមានឡើងទោះបីជាច្រើនឆ្នាំក្រោយមកក្តី តាមធម្មតាពេលណាប្រព័ន្ធស៊ាំនឹងរោគរបស់ដងខ្លួនវាខ្សោយ។ ការនេះអាចកើតមានឡើងដោយព្រោះតែចូលវ័យចំណាស់ មានជម្ងឺធ្ងន់ធ្ងរ ប្រើគ្រឿងញៀន ឬសុរា មានរោគ HIV (មេរោគដែលបណ្តាលឲ្យកើតជម្ងឺអេដស៍) ឬលក្ខណៈរោគឯទៀត។

| **រោគ TB** | **ជម្ងឺ TB** |
| --- | --- |
| មានមេរោគ TB អសកម្មនៅក្នុងដងខ្លួន | មានមេរោគ TB សកម្មនៅក្នុងដងខ្លួន |
| ឥតមានរោគសញ្ញានៃ TB | មានរោគសញ្ញានៃ TB ទាំងឡាយមានដូចជាក្អក គ្រុន ស្រកទម្ងន់ |
| មិនអាចចម្លងមេរោគ TB ទៅអ្នកឯទៀតទេ | អាចចម្លងមេរោគ TB ទៅអ្នកឯទៀត |
| អាចត្រូវការការព្យាបាលរោគ TB ដើម្បីការពារកុំឲ្យកើតក្លាយទៅជាជម្ងឺ TB | ត្រូវទទួលការព្យាបាលដើម្បីឲ្យបានជាពីជម្ងឺ TB |

### តើមានការព្យាបាលណាខ្លះសំរាប់រោគ TB?

- ថ្នាំព្យាបាលធម្មតាប្រើសំរាប់ការពាររោគ TB គឺ Isoniazid ក៏ប៉ុន្តែគេអាចប្រើថ្នាំព្យាបាលឯទៀតផងដែរ។
- ត្រូវលេបថ្នាំព្យាបាលទាំងនេះរៀងរាល់ថ្ងៃ ឲ្យបានយ៉ាងហោចណាស់៦ខែ ដ្បិតអីវាត្រូវការរយៈពេលវែងយ៉ាងនេះ ដើម្បីសម្លាប់មេរោគ TB អសកម្ម។
- លោកអ្នកប្រហែលជាបានទទួលថ្នាំព្យាបាល pyridoxine (វីតាមីន B6) ដើម្បីបង្ការប្រតិកម្មរាយរងដែលអាចកើតមាននៃថ្នាំ Isoniazid។

### ខ្ញុំមិនឈឺទេ តើខ្ញុំត្រូវលេបថ្នាំដែរឬទេ?

- ទោះបីជាលោកអ្នកមិនឈឺក្តី ការព្យាបាលរោគ TB នៅក្នុងដំណាក់កាលដំបូងអាចសម្លាប់មេរោគ TB ដែលមាននៅក្នុងដងខ្លួនរបស់លោកអ្នក ហើយជួយការពារលោកអ្នកឲ្យរួចផុតពីការកើតមាននៃជម្ងឺ TB។
- ការព្យាបាលរោគ TB អាចជួយបង្ការជម្ងឺ TB នៅក្នុងចំនួនមនុស្សភាគច្រើនដែលបញ្ចប់ការប្រើថ្នាំព្យាបាលលេញលេញ។

### តើការព្យាបាលរោគ TB មានសុវត្ថិភាពឬទេ?

- ថ្នាំព្យាបាលទាំងនេះមានសុវត្ថិភាព ហើយមនុស្សភាគច្រើន (មានរួមទាំងកុមារ) ពុំមានបទពិសោធន៍នឹងបញ្ហាណាមួយឡើយ ពេលណាគេប្រើថ្នាំទាំងនេះ។
- អ្នកខ្លះអាចមានប្រតិកម្មរាយរងទាំងឡាយ មានរួមទាំង:
    - ឈឺពោះ
    - ស្បែក ឬភ្នែកលឿង
    - ទឹកមូត្រពណ៌ខ្មៅ (ដូចតែខ្មៅ ឬកាហ្វេខ្មៅ)
    - លែងចង់ពិសាម្ហូបអាហារ
    - វិលមុខ ឬចង់ក្អួត
    - ឡើងកន្ទួល ឬរមាស់
    - គ្រុន
    - អស់កម្លាំងយ៉ាងខ្លាំង
    - ឈឺឆៀបៗនៅត្រង់ម្រាមដៃ ឬម្រាមជើង។

សូមប្រាប់វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាករបស់លោកអ្នកឲ្យបានភ្លាម ប្រសិនបើលោកអ្នកមានប្រតិកម្មរាយរងទាំងនេះណាមួយ ឬប្រតិកម្មរាយរងឯទៀតដែលលោកអ្នកមានកង្វល់។ ប្រតិកម្មរាយរងមួយដែលកម្រនឹងឃើញមាន ក៏ប៉ុន្តែមានភាពធ្ងន់ធ្ងរគឺការខូចថ្លើម ហើយជាទូទៅការនេះអាចចៀសវាងបាន ដោយមានការពិនិត្យឃ្លាំមើលយ៉ាងយកចិត្តទុកដាក់ពីវេជ្ជបណ្ឌិតរបស់លោកអ្នក។

### តើខ្ញុំគួរប្រើថ្នាំពេទ្យដោយបែបណា?

- លោកអ្នកគួរលេបថ្នាំពេទ្យទាំងអស់ក្នុងពេលជាមួយគ្នា ឲ្យបានរៀងរាល់ថ្ងៃ។
- ដើម្បីជួយលោកអ្នកឲ្យបានចាំក្នុងការលេបថ្នាំពេទ្យរបស់លោកអ្នក លោកអ្នកអាចយល់ឃើញថាមានប្រយោជន៍ដោយគូសសញ្ញាសំគាល់នៅពីលើប្រក្រតិទិន ឬសៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់លោកអ្នក ឬលេបថ្នាំពេទ្យរបស់លោកអ្នកមួយម៉ោងមុនពេលពិសាម្ហូបអាហារណាមួយរបស់លោកអ្នក។

- ប្រសិនបើលោកអ្នកភ្លេចលេបថ្នាំរបស់លោកអ្នកនៅថ្ងៃណាមួយ សូមគ្រាន់តែលេបកម្រិតថ្នាំធម្មតានៅថ្ងៃបន្ទាប់ទៀតប៉ុណ្ណោះ (ក៏ប៉ុន្តែកុំលេបកម្រិតថ្នាំ២ដងនៅថ្ងៃបន្ទាប់ឲ្យសោះ)។ ប្រសិនបើលោកអ្នកភ្លេចលេបច្រើនដងពេក ថ្នាំនោះប្រហែលជាមិនមានប្រសិទ្ធិភាពនឹងសម្លាប់មេរោគ TB ទាំងអស់ឡើយ។ លោកអ្នកគួរប្រាប់វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាករបស់លោកអ្នកឲ្យបានដឹង ប្រសិនបើលោកអ្នកចេះតែភ្លេចលេបថ្នាំរបស់លោកអ្នក។
- លោកអ្នកមិនគួរពិសាសុរាឡើយ ក្នុងកាលកំពុងលេបថ្នាំពេទ្យរបស់លោកអ្នក។ សូមឆែកមើលជាមួយវេជ្ជបណ្ឌិតរបស់លោកអ្នក មុននឹងលោកអ្នកលេបថ្នាំព្យាបាលថ្មីណាមួយ (មានរួមទាំងថ្នាំទិញពីឱសថស្ថានដោយឥតមានសំបុត្រពេទ្យ ឬថ្នាំបន្ថែមណាមួយ ដូចជាថ្នាំផារ៉ាស៊ីតាម៉ុល) ដ្បិតអីថ្នាំខ្លះប៉ះពាល់ដល់ថ្នាំពេទ្យឯទៀតប្រើសំរាប់បង្ការរោគ TB។

## តើខ្ញុំត្រូវប្រាប់នរណាម្នាក់ឬទេ អំពីថ្នាំព្យាបាលរោគ TB របស់ខ្ញុំ?

- អស់អ្នកដែលមានរោគ TB តែមួយមុខនោះមិនអាចចម្លងរោគ TB ទៅអ្នកផ្សេងទៀតឡើយ ដូច្នេះមិនចាំបាច់ប្រាប់អ្នកឯទៀតនៅកន្លែងធ្វើការ សាលារៀន ឬសាកលវិទ្យាល័យឡើយ ប្រសិនបើលោកអ្នកមិនចង់ធ្វើយ៉ាងដូច្នោះ។ លោកអ្នកគួរប្រាប់វេជ្ជបណ្ឌិតឯទៀតដែលលោកអ្នកទៅជួប ហើយគេនឹងរក្សាទុកព័ត៌មាននេះជាសម្ងាត់។

## កិច្ចការឯទៀតដែលត្រូវពិចារណា

ក្រៅពីកិច្ចការដូចបានរៀបរាប់ខាងលើនេះ:

- អ្នកគួរប្រាប់វេជ្ជបណ្ឌិតរបស់អ្នក ប្រសិនបើអ្នកមានបញ្ហាសុខភាពឯទៀត ឬអ្នកមានបំណងចង់មានផ្ទៃពោះ។
- លោកអ្នកអាចបន្តធ្វើសកម្មភាពធម្មតាទាំងឡាយរបស់លោកអ្នក ក្នុងកាលកំពុងលេបថ្នាំពេទ្យនេះ។

## ដើម្បីទទួលយកព័ត៌មានច្រើនថែមទៀត

- ក្នុងអំឡុងពេលដែលលោកអ្នកកំពុងលេបថ្នាពេទ្យ វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាកនឹងពិនិត្យមើលលោកអ្នកយ៉ាងទៀងទាត់ដើម្បីឆែកមើលដំណើរជាគ្រាន់បើឡើងវិញរបស់លោកអ្នក ក៏ប៉ុន្តែប្រសិនបើលោកអ្នកមានបំណងចង់ទទួលយកព័ត៌មានច្រើនថែមទៀត សូមទាក់ទងជាមួយគិលានដ្ឋានថតពិនិត្យមើលដើមទ្រូងប្រចាំតំបន់របស់លោកអ្នក ឬទៅជួបវេជ្ជបណ្ឌិតប្រចាំតំបន់របស់លោកអ្នក។